**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**
គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩
ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩)
លេខ ៣២១/២២ គ.វ.ក-១៩

ថ្ងៃ អង្គារ ១៣ រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០២២

# សេចក្តីជូនព័ត៌មាន
## ស្តីពី
## ការក្រើនរំលឹក នៃការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ និងដូសទី២ (ដូសមូលដ្ឋាន) និងដូសទី៣ ឬដូសជំរុញ

គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (**គ.វ.ក-១៩**) សូមជម្រាបជូនសាធារណជនជ្រាបថា ដើម្បីបង្កើនឱ្យមាន ភាពស៊ាំរបស់បុគ្គល ក៏ដូចជាបង្កើនភាពស៊ាំក្នុងសហគមន៍ទប់ទល់នឹងការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ស្របពេលដែលមានការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ គួរឱ្យព្រួយបារម្ភក្នុងពេលបច្ចុប្បន្ននេះ **គ.វ.ក-១៩** សូមធ្វើការក្រើនរំលឹកដល់សាធារណជនទាំងអស់ សូមអញ្ជើញទៅទទួលការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ និងដូសទី២ (ដូសមូលដ្ឋាន) និងដូសទី៣ ឬដូសជំរុញ ដូចខាងក្រោម៖

- ចំពោះកុមារអាយុចាប់ពី ៣ឆ្នាំ ដល់អាយុក្រោម ៥ឆ្នាំ សូមអញ្ជើញទៅទទួលការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ និងដូសទី២) ដូសមូលដ្ឋាន (ឱ្យបានគ្រប់ៗគ្នា នៅតាមទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ដែលកំពុងបន្តយុទ្ធនាការចាក់ជូនក្នុងពេលបច្ចុប្បន្ន។
- ចំពោះកុមារ យុវវ័យ និងប្រជាពលរដ្ឋមានអាយុចាប់ពី៥ឆ្នាំឡើង ដែលមិនទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ សូមអញ្ជើញទៅទទួលយកការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ ឱ្យបានគ្រប់ៗគ្នា និងសូមអញ្ជើញទៅទទួលយកវ៉ាក់សាំងកូវីដ-១៩ ដូសទី២ នៅពេលដែលដល់ពេលវេលាកំណត់ត្រូវចាក់ដូសទី២។
- ចំពោះកុមារ ដែលមានអាយុចាប់ពី៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ និងប្រជាពលរដ្ឋដែលមានអាយុចាប់ពី១៨ឆ្នាំឡើង ទាំងអស់ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ និងដូសទី២ រួចរាល់ ឬបានចាក់វ៉ាក់សាំងចនសុន និងចនសុន មួយដូសរួច ហើយមានគម្លាតចាប់ពី៤ខែឡើង បន្ទាប់ពីការចាក់វ៉ាក់សាំងដូសទី២ ឬបន្ទាប់ពីការចាក់វ៉ាក់សាំងចនសុន និងចនសុន មួយដូសរួច សូមរួសរាន់អញ្ជើញទៅចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ ឱ្យបានគ្រប់ៗគ្នា។
- ចំពោះកុមារអាយុ៥ឆ្នាំ សូមទៅទទួលការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ ដែលនឹងចាប់ផ្តើមចាក់ជូនចាប់ពី **ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២**។

ចំពោះទីតាំងនៃការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនគ្រប់ក្រុមអាយុដែលបានរៀបរាប់ជូនខាងលើគឺមាននៅតាមមន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព ឬទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ដែលស្ថិតនៅជិតទីសំណាក់របស់បងប្អូន ដូចដែល **គ.វ.ក-១៩** ក៏ដូចជារដ្ឋបាលរាជធានី-ខេត្ត បានចេញសេចក្តីជូនព័ត៌មាន ឬការណែនាំដោយឡែកជាហូរហែកន្លងមក ។



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរសព្ទ-ទូរសារ៖ (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩

**គ.វ.ក-១៩** សូមអំពាវនាវដល់ពុក ម៉ែ បង ប្អូន អាណាព្យាបាល ក្មួយៗ ប្រជាពលរដ្ឋ គ្រប់ក្រុមអាយុទាំងអស់ចាប់ពី៣ឆ្នាំឡើង ដែលមិនទាន់បានចាក់វ៉ាក់សាំងដូសទី១ និងដូសទី២ (ដូសមូលដ្ឋាន) និងដូសទី៣ ឬដូសជំរុញ សូមអញ្ជើញទៅទទួលយកការចាក់វ៉ាក់សាំងដូសទី១ និងដូសទី២ (ដូសមូលដ្ឋាន) និងដូសទី៣ ឬដូសជំរុញ ឱ្យបានគ្រប់ៗគ្នា ដូចបានក្រើនរំលឹកជូនខាងលើនេះស្រាប់។

លើសពីនេះ **គ.វ.ក-១៩** សូមគោរពជម្រាបជូនផងដែរថា ទោះបីជាបុគ្គលម្នាក់ៗបានទទួលការចាក់វ៉ាក់សាំងកូវីដ-១៩ រួចរាល់ហើយក្តី ក៏ត្រូវបន្តអនុវត្តនូវវិធានការ «**៣ការពារ**» (ពាក់ម៉ាស់ លាងដៃញឹកញាប់ និងរក្សាគម្លាតសុវត្ថិភាពបុគ្គលពី មួយម៉ែត្រកន្លះឡើងទៅ) និង «**៣កុំ**» (កុំទៅកន្លែងដែលមានមនុស្សច្រើនកុះករ កុំទៅកន្លែងដែលបិទជិតគ្មានខ្យល់ចេញចូល កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា កុំកៀកស្មាគ្នា) តាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងបន្តរួមគ្នាអនុវត្តតាមយុទ្ធនាការជាតិអប់រំក្រោមប្រធានបទ «*រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩*» ក៏ដូចជាគោរពតាមសេចក្តីណែនាំក្រើនរំលឹកដែលធ្លាប់បានចេញផ្សាយជូនជាហូរហែ របស់ក្រសួងសុខាភិបាល ស្តីពីការបន្តការការពារការចម្លងវីរុសកូវីដ-១៩ ជាពិសេស អូមីក្រុង ដើម្បីចូលរួមទប់ស្កាត់ការចម្លងវីរុស កូវីដ-១៩ នៅក្នុងសហគមន៍ នៃប្រទេសកម្ពុជា និងរក្សានិរន្តរភាព នៃការរស់នៅតាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃការប្រយុទ្ធនឹងជំងឺកូវីដ-១៩។

ប្រសិនបើបងប្អូនប្រជាពលរដ្ឋមានចម្ងល់ពាក់ព័ន្ធទៅនឹងការចាក់វ៉ាក់សាំងកូវីដ-១៩ សូមទំនាក់ទំនងមកកាន់លេខទូរស័ព្ទខាងក្រោម៖

ក-ក្រុមការងារទំនាក់ទំនងសាធារណៈ / លេខាធិការដ្ឋាន៖

| | | |
|---|---|---|
| ០១២ ៩៨៩ ០៨៥ | ០១២ ៩១៦ ០៩៩ | ០១០ ២៣៣ ៥៨៨ |

ខ-ក្រុមការងារចុះឈ្មោះ និងប្រព័ន្ធព័ត៌មានវិទ្យា៖

| | | |
|---|---|---|
| ០១២ ៨៩៧ ០៤៣ | ០៦៨ ៩០៦ ៦៦៦ | ០១២ ៨៦៨ ៦៤០ |

គ-ក្រុមការងារសុវត្ថិភាពវ៉ាក់សាំង និងប្រាស្រ័យទាក់ទងហានិភ័យ៖

| | | |
|---|---|---|
| ០១២ ៨៨៧ ៣៨៧ | ០១២ ៨៣៦ ៨៦៨ | ០១២ ៨៩១ ៥២៧ |

**រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មការចំពោះកិច្ច**
**ចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩)**

**វេជ្ជបណ្ឌិត ឱ វណ្ណឌីន**



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរសព្ទ-ទូរសារ៖ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩